ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ

# ស្តីពី

# ភាសាខ្មែរ

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## អារម្ភកថា

នៅគ្រប់សម័យកាល បុព្វបុរសខ្មែរតែងតែយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សានិងការការពារភាសានិងអក្សរខ្មែរឱ្យនៅគង់វង្សជារៀងរហូតមកដល់បច្ចុប្បន្ន។

ភាសានៃជនជាតិនីមួយៗនៅលើពិភពលោកតែងតែមានការវិវត្តទៅតាមតម្រូវការសង្គមនិងសម័យកាល។ ដូចគ្នានេះដែរ ភាសាខ្មែរក៏មានការវិវត្តជាច្រើនដំណាក់កាលទាំងពាក្យ ទាំងទម្រង់អក្សរដែលមានភស្តុតាងនៅលើផ្ទាំងសិលាចារឹកតាមប្រាសាទនានា ក្នុងសាស្ត្រាស្លឹករឹតនិងក្រាំងតាមវត្តអារាមក្នុងវចនានុក្រមនិងឯកសារផ្សេងៗ ជាដើម។ ក្នុងគ្រប់ដំណាក់កាលនៃប្រវត្តិសាស្ត្រ បុព្វបុរសខ្មែរ ជាពិសេសព្រះសង្ឃបានខិតខំពុះពារអភិរក្សនិងអភិវឌ្ឍភាសានិងអក្សរខ្មែរឱ្យនៅគង់វង្សរហូតមក។

ភាសាខ្មែរមានការរីកចម្រើននិងឈានទៅធ្វើស្តង់ដានីយកម្មចាប់ពីពេលដែលព្រះបាទស៊ីសុវត្ថិបានត្រាស់បង្គាប់ឱ្យបង្កើតក្រុមជំនុំមួយនៅឆ្នាំ១៩១៥ ដើម្បីរៀបចំធ្វើវចនានុក្រមខ្មែរជាលើកដំបូង។ នៅឆ្នាំ១៩៣៤ ក្រុមជំនុំមួយទៀតត្រូវបានបង្កើតឡើង ដែលក្រោយមកមានឈ្មោះថា គណៈកម្មការវប្បធម៌សម្រាប់បង្កើតបច្ចេកសព្ទថ្មីៗ និងបន្ទាប់មកទៀតមានការបង្កើតគណៈកម្មាធិការជាតិខេមរយានកម្មនៅឆ្នាំ១៩៦៧។

បន្ទាប់ពីបានរំដោះប្រទេសកម្ពុជាឱ្យរួចផុតពីរបបប្រល័យពូជសាសន៍នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលនិងប្រជាជនកម្ពុជាបានខិតខំស្តារនិងកសាងប្រទេសពីបាតដៃទទេឱ្យមានការរីកចម្រើនជាបណ្តើរៗលើគ្រប់វិស័យ ក្នុងនោះរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ខ្ពស់ផងដែរក្នុងការប្រើប្រាស់ភាសានិងអក្សរខ្មែរដែលជាអត្តសញ្ញាណជាតិ។

ទន្ទឹមនឹងការវិវត្តនៃសង្គម ក្នុងរយៈពេលកន្លងមក ការប្រើប្រាស់ភាសាខ្មែរមិនទាន់មានការឯកភាពគ្នាទាំងស្រុងនៅឡើយ។ ដើម្បីដោះស្រាយបញ្ហានេះ អ្នកជំនាញភាសានិងថ្នាក់ដឹកនាំបានខិតខំជាជំហានៗដោយស្មារតីប្រុងប្រយ័ត្ននិងការទទួលខុសត្រូវខ្ពស់ក្នុងការកំណត់គោលការណ៍នៃការប្រើប្រាស់ភាសាខ្មែរ។ លើសពីនេះទៅទៀត ភាសានិងអក្សរខ្មែរត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ជាភាសានិងអក្សរផ្លូវការសម្រាប់ការប្រើប្រាស់និងការប្រាស្រ័យទាក់ទងគ្នាលើគ្រប់វិស័យស្របតាមតម្រូវការ ដើម្បីធ្វើឱ្យមានសុខដុមរមនាក្នុងការអភិវឌ្ឍសង្គមជាតិ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានបង្កើតវិទ្យាស្ថានភាសាជាតិនៅឆ្នាំ១៩៩៨ និងបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរនៅឆ្នាំ២០០៧ ហើយគណៈកម្មាធិការនេះបានប្តូរទៅជាក្រុមប្រឹក្សាជាតិភាសាខ្មែរនៅឆ្នាំ២០១១និងប្រគល់ឱ្យក្រុមប្រឹក្សាជាតិភាសាខ្មែររៀបចំគោលនយោបាយជាតិស្តីពីភាសាខ្មែរនៅឆ្នាំ២០១៨ ដើម្បីបន្តដោះស្រាយបញ្ហានានាដែលទាក់ទងនឹងភាសាខ្មែរ និងធ្វើជាឯកសារតម្រង់ទិសក្នុងការប្រើប្រាស់ ការអភិរក្សនិងការអភិវឌ្ឍភាសាខ្មែរ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិនិងឯកភាពជាតិផងដែរ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា គោលនយោបាយជាតិនេះនឹងបម្រើជាឧត្តមប្រយោជន៍ដ៏មានប្រសិទ្ធភាពខ្ពស់ក្នុងការប្រើប្រាស់ភាសាខ្មែរឱ្យបានត្រឹមត្រូវនិងទូលំទូលាយដើម្បីរក្សាអត្តសញ្ញាណជាតិ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងប្រទេស តំបន់ និងពិភពលោក ដែលកំពុងអភិវឌ្ឍឥតឈប់ឈរ និងឆាប់រហ័ស។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមវាយតម្លៃខ្ពស់និងកោតសរសើរចំពោះគណៈកម្មការរៀបចំគោលនយោបាយជាតិស្តីពីភាសាខ្មែរនៃក្រុមប្រឹក្សាជាតិភាសាខ្មែរនិងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមរៀបចំគោលនយោបាយនេះឡើងប្រកបដោយជោគជ័យ។

ថ្ងៃព្រហស្បតិ៍ ១៥កើតខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៩

ហ៊ុន សែន

# មាតិកា


អារម្ភកថា ................................................ i

១. សេចក្តីផ្តើម ................................................ ១

២. ចក្ខុវិស័យ ................................................ ២

៣. គោលបំណង ................................................ ២

៤. គោលដៅ ................................................ ២

៥. យុទ្ធសាស្ត្រ ................................................ ៣

៦. ផែនការសកម្មភាព ................................................ ៤

៧. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ ................................................ ៥

៨. សេចក្តីសន្និដ្ឋាន ................................................ ៥

សន្ទានុក្រម ................................................ ៦

## ១. សេចក្តីផ្តើម

ជនជាតិខ្មែរគឺជាក្រុមមនុស្សមួយក្រុមក្នុងចំណោមពួកមនុស្សដំបូងៗបង្អស់ដែលរស់នៅលើទឹកដីដ៏ធំធេងនៃតំបន់អាស៊ីអាគ្នេយ៍។ ភស្តុតាងខាងបុរាណវត្ថុវិទ្យាបង្ហាញថា នៅលើទឹកដីកម្ពុជាមានមនុស្សរស់នៅចាប់តាំងពីសម័យបុរេប្រវត្តិសាស្ត្រមក ដូចជា លលាដ៍ក្បាលនិងឆ្អឹងមនុស្សដែលបានរកឃើញនៅស្ថានីយសំរោងសែន ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ចុះកាលបរិច្ឆេទ១១៥០០ឆ្នាំមុនគ.ស.។ អាណាចក្រហ្វូណានមានអាយុកាលពីសតវត្សរ៍ទី១ដល់ទី៦នៃគ.ស. បន្ទាប់មកអាណាចក្រចេនឡាបានចាប់ផ្តើមពីសតវត្សរ៍ទី៦ដល់ទី៨នៃគ.ស. ហើយបានក្លាយជាអាណាចក្រអង្គរដែលលាតសន្ធឹងដ៏ធំធេង ក្នុងតំបន់អាស៊ីអាគ្នេយ៍ចាប់ពីសតវត្សរ៍ទី៩ដល់ទី១៥នៃគ.ស.។ អាណាចក្រនេះបានបន្សល់ទុកនូវប្រាសាទបុរាណរាប់ពាន់ដោយរាប់បញ្ចូលទាំងប្រាសាទអង្គរវត្តដ៏ល្បីល្បាញផងដែរ។ កិត្យានុភាពរបស់អាណាចក្រអង្គរបានធ្លាក់ចុះចាប់ពីឆ្នាំ១៤៣១មក ហើយចាប់ពីឆ្នាំ១៨៦៣ដល់ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានស្ថិតនៅក្រោមអាណាព្យាបាលបារាំង។

បច្ចុប្បន្នកាលនេះ ជនជាតិខ្មែរគឺជាក្រុមជនជាតិមានចំនួនច្រើនប្រមាណជា៩០%នៃចំនួនប្រជាជនសរុបនៅប្រទេសកម្ពុជា។ ជនជាតិខ្មែរមានវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី និងភាសារបស់ខ្លួនជាយូរយារណាស់មកហើយ។ ភាគច្រើននៃជនជាតិខ្មែរជាអ្នកកាន់ព្រះពុទ្ធសាសនា។

ភាសាខ្មែរដែលជាភាសាមតេកផ្ទាល់នៃភាសាខ្មែរបុរាណ គឺជាភាសាមួយក្នុងចំណោមភាសាប្រមាណជា១៤៤នៃសាខាភាសាមន ខ្មែរក្នុងអម្បូរភាសាអូស្ត្រូអាស៊ី។ ភាសាខ្មែរបុរាណនៅតែមានសារៈសំខាន់ ដោយហេតុថា ភាសាមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដូចជាភាសាថៃ ភាសាឡាវ ភាសាកួយ ភាសាព្នង ភាសាស្អៀង និងភាសាជនជាតិដើមភាគតិចដទៃទៀត សុទ្ធតែទទួលឥទ្ធិពលពីភាសាខ្មែរ។ ចំណែកឯភាសាខ្មែរផ្ទាល់ក៏បានវិវត្តក្នុងប្រវត្តិដ៏យូរលង់របស់ខ្លួន និងបានទទួលឥទ្ធិពលពីភាសានិងវប្បធម៌ឥណ្ឌាភាគខាងត្បូង ដែលជាហេតុនាំឱ្យមានការខ្ចីពាក្យពីភាសាសំស្ក្រឹតនិងភាសាបាលីមកប្រើក្នុងភាសាខ្មែរ ដែលភាគច្រើនក្នុងវិស័យទស្សនវិជ្ជា សាសនា ច្បាប់ រដ្ឋបាល អប់រំ ផ្នែកបច្ចេកទេសនានា ជាដើម។ ដោយហេតុថាប្រទេសកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលបារាំងជិតមួយសតវត្សរ៍ ភាសាខ្មែរក៏បានទទួលឥទ្ធិពលពីភាសាបារាំង ហើយភាសានេះត្រូវបានប្រើជាភាសាសំខាន់មួយ។ ភាសាបារាំងបានចាប់ផ្តើមថមថយឥទ្ធិពល ចាប់ពីពាក់កណ្តាលទី២នៃសតវត្សរ៍ទី២០ ក្រោយប្រទេសកម្ពុជាទទួលបានឯករាជ្យ។ ចាប់តាំងពីឆ្នាំ១៩៩៣ ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្សនិងដោយសារឥទ្ធិពលនៃសាកលភាវូបនីយកម្ម ភាសាអង់គ្លេសបានក្លាយជាភាសាសំខាន់មួយ។

ទន្ទឹមនឹងការវិវត្តនេះ អក្សរខ្មែរក៏មានប្រវត្តិដ៏យូរលង់របស់ខ្លួនផងដែរ។ សិលាចារឹករាប់រយផ្ទាំងដែលមានចុះកាលបរិច្ឆេទពីសតវត្សរ៍ទី៧ដល់ទី១៥នៃគ.ស. ដែលត្រូវបានគេរកឃើញរហូតមកដល់សព្វថ្ងៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅភាគខាងត្បូងនៃប្រទេសវៀតណាម នៅប្រទេសថៃ និងនៅប្រទេសឡាវ ជាអំណះអំណាងអំពីអត្ថិភាពនិងកិត្យានុភាពនៃភាសាខ្មែរបុរាណ។ សិលាចារឹកនៅអង្គរបុរីចុះកាលបរិច្ឆេទឆ្នាំ៦១១នៃគ.ស. ត្រូវបានចាត់ទុកថាជាសិលាចារឹកជាភាសាខ្មែរដំបូងដែលបានខ្ចីអក្សរព្រាហ្មីនៃឥណ្ឌាភាគខាងត្បូង។ អក្សរខ្មែរបុរាណនេះមានការវិវត្តធំៗចំនួន[illegible] មកដល់បច្ចុប្បន្ន ដែលមានប្រភពពីសណ្ឋានគឺអក្សរមូលនិងអក្សរជ្រៀង។

**-គោលនយោបាយភាសា-** ត្រូវបានធ្វើស្ថាប័ននីយកម្មក្នុងបរិបទប្រទេសជាច្រើនក្នុងពិភពលោក ក៏ដូចជាក្នុងតំបន់ប្រមាណជិតបួនទសវត្សរ៍មកហើយ ហើយការរៀបចំ **-គោលនយោបាយភាសា-** នីមួយៗ នោះធ្វើឱ្យមានការផ្លាស់ប្តូរជាថ្មីមានក្នុងការប្រើភាសារបស់ខ្លួនសម្រាប់ជាមូលដ្ឋានគ្រឹះនៃសុខដុមនីយកម្មសង្គមនិងកំណើនសេដ្ឋកិច្ច។

ក្នុងបច្ចុប្បន្ននេះ ការប្រើភាសាខ្មែរដូចជាសំណេរ ការបន្លឺសូរភាសា ក្បួនវេយ្យាករណ៍ខ្មែរ ជាដើម នៅពុំទាន់មានលក្ខណៈស្តង់ដាគ្រប់គ្រាន់នៅឡើយ ថ្វីត្បិតតែយើងបានយកវចនានុក្រមខ្មែរបោះពុម្ពគ្រាទី៥ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧-១៩៦៨ ជាគោលក៏ដោយ។ ជាងនេះទៅទៀត អស់រយៈពេលជាងកន្លះសតវត្សរ៍មកហើយ វចនានុក្រមនេះក៏នៅមិនទាន់ត្រូវបានធ្វើបច្ចុប្បន្នកម្មឱ្យស្របទៅនឹងសេចក្តីត្រូវការក្នុងការប្រើភាសាខ្មែរនៅឡើយ។

ម្យ៉ាងវិញទៀត ការប្រើភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយមាន ទូរទស្សន៍ វិទ្យុ បណ្តាញសង្គមនានា បណ្តាញសារព័ត៌មាន ប្រព័ន្ធអ៊ីនធឺណិត។ល។ និងលើរូបសញ្ញា ឈ្មោះស្ថាប័ន ឈ្មោះប្រទេស ឈ្មោះទីកន្លែង នៅមានកំហុសឆ្គងនិងមិនទាន់ឯកភាពគ្នា។

ទោះជាស្ថិតក្នុងស្ថានភាពដូចនេះក៏ដោយ ក៏តម្រូវការប្រើភាសាខ្មែរនៅតែមានការកើនឡើងខ្ពស់ដែរ ជាពិសេស ក្នុងវិស័យពាណិជ្ជកម្ម ទេសចរណ៍ បរិស្ថាន បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ល។ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនយ៉ាងលឿននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា សង្គម និងសេដ្ឋកិច្ច។

ក្នុងគោលបំណងលើកកម្ពស់ភាសាខ្មែរ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាកំណត់ថា ភាសានិងអក្សរដែលប្រើជាផ្លូវការគឺភាសានិងអក្សរខ្មែរ ហើយរដ្ឋមានកាតព្វកិច្ចការពារនិងពង្រីកភាសាខ្មែរឱ្យសមស្របនឹងសេចក្តីត្រូវការ។

អនុលោមតាមន័យខាងលើនេះ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិភាសាខ្មែរនិងដាក់ចេញគោលនយោបាយជាតិស្តីពីភាសាខ្មែរនេះ សម្រាប់ជាផែនទីបង្ហាញផ្លូវ ដើម្បីធានាការអភិរក្ស ការអភិវឌ្ឍ ទំនើបកម្ម ការឯកភាពក្នុងការប្រើភាសាខ្មែរ និងដោះស្រាយបញ្ហាទាំងឡាយទាក់ទងនឹងភាសាខ្មែរ។

## ២. ចក្ខុវិស័យ

គោលនយោបាយជាតិស្តីពីភាសាខ្មែរមានចក្ខុវិស័យលើកកម្ពស់កិត្យានុភាពភាសាខ្មែរប្រកបដោយនិរន្តរភាពដើម្បីរក្សាអត្តសញ្ញាណជាតិខ្មែរ។

## ៣. គោលបំណង

គោលនយោបាយជាតិស្តីពីភាសាខ្មែរមានគោលបំណងអភិរក្សនិងអភិវឌ្ឍភាសាខ្មែរប្រកបដោយភាពសុខដុម។

## ៤. គោលដៅ

គោលនយោបាយជាតិស្តីពីភាសាខ្មែរមានគោលដៅ៖

៤.១- បង្កើតយន្តការនិងកំណត់គោលការណ៍ក្នុងការអភិរក្សនិងការអភិវឌ្ឍភាសាខ្មែរ។

៤.២- បង្កើនការប្រើភាសាខ្មែរជាភាសាយានដើម្បីទទួលយកចំណេះដឹងនិងជំនាញ[illegible] ទូលំទូលាយ។

៤.៣. ជំរុញនិងលើកកម្ពស់ការប្រើពាក្យនិងបច្ចេកសព្ទជាភាសាខ្មែរ និងជំរុញការប្រើពាក្យនិងបច្ចេកសព្ទកម្ចីឱ្យស្របតាមគោលការណ៍ភាសាជាតិ។

៤.៤. ជំរុញនិងលើកកម្ពស់ការប្រើភាសាខ្មែរឱ្យបានទូលំទូលាយនិងត្រឹមត្រូវ។

៤.៥. កំណត់និងត្រួតពិនិត្យឱ្យមានឯកភាពក្នុងការប្រើភាសាខ្មែរ។

៤.៦. ជំរុញនិងលើកកម្ពស់ការស្រាវជ្រាវ ការប្រមូល ការចងក្រង ការថែរក្សា និងការផ្សព្វផ្សាយឯកសារទាក់ទងនឹងភាសាខ្មែរ។

## ៥. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅដែលបានកំណត់ខាងលើ និងដើម្បីឱ្យគោលនយោបាយជាតិស្ដីពីភាសាខ្មែរនេះអនុវត្តទៅប្រកបដោយភាពរលូននិងមានប្រសិទ្ធភាព ត្រូវមានយុទ្ធសាស្ត្រដូចខាងក្រោម៖

### ៥.១. បង្កើតយន្តការនិងកំណត់គោលការណ៍ក្នុងការអភិរក្សនិងការអភិវឌ្ឍភាសាខ្មែរ

៥.១.១. ពង្រឹងអភិបាលកិច្ចល្អក្នុងក្របខណ្ឌយន្តការនានាទាក់ទងនឹងភាសាខ្មែរ។

៥.១.២. រៀបចំលិខិតបទដ្ឋានគតិយុត្តនិងយន្តការនានាដើម្បីអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព។

៥.១.៣. បណ្ដុះបណ្ដាលធនធានមនុស្សដើម្បីអភិរក្សនិងអភិវឌ្ឍភាសាខ្មែរ។

៥.១.៤. កំណត់ឱ្យមានកម្មវិធីរៀនភាសាខ្មែរនៅគ្រឹះស្ថានសិក្សាឯកជន។

៥.១.៥. ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងភាសាខ្មែរ។

### ៥.២. បង្កើនការប្រើភាសាខ្មែរជាភាសាយាន ដើម្បីទទួលយកចំណេះដឹងនិងជំនាញផ្សេងៗឱ្យបានទូលំទូលាយ

៥.២.១. ជំរុញការចងក្រង ការរៀបរៀង ការនិពន្ធ និងការផ្សព្វផ្សាយឯកសារភាសាខ្មែរ។

៥.២.២. លើកទឹកចិត្តការបកប្រែសៀវភៅ ឯកសារនានាពីភាសាបរទេសមកជាភាសាខ្មែរ។

៥.២.៣. យកចិត្តទុកដាក់ការប្រើភាសាខ្មែរក្នុងផ្នែកបច្ចេកវិទ្យា។

### ៥.៣. ជំរុញនិងលើកកម្ពស់ការប្រើពាក្យនិងបច្ចេកសព្ទជាភាសាខ្មែរ ព្រមទាំងពាក្យនិងបច្ចេកសព្ទកម្ចីឱ្យស្របតាមគោលការណ៍ភាសាជាតិ

៥.៣.១. ផ្សព្វផ្សាយអំពីការប្រើភាសាខ្មែរនិងសមិទ្ធផលរបស់ក្រុមប្រឹក្សាជាតិភាសាខ្មែរតាមប្រព័ន្ធផ្សព្វផ្សាយជាតិ ឯកជន និងមធ្យោបាយផ្សេងៗទៀត ដើម្បីអនុវត្តឱ្យបានទូលំទូលាយ។

៥.៣.២. សម្របសម្រួលការបង្កើតពាក្យនិងបច្ចេកសព្ទជាភាសាខ្មែរជាមួយក្រសួង ស្ថាប័នរដ្ឋ និងផ្នែកឯកជននានា។

៥.៣.៣. កំណត់គោលការណ៍ស្ដីពីការកត់សូរភាសាបរទេសជាអក្សរខ្មែរនិងការកត់សូរភាសាខ្មែរជាអក្សរឡាតាំងបែបខ្មែរ។

### ៥.៤. ជំរុញនិងលើកកម្ពស់ការប្រើភាសាខ្មែរឱ្យបានទូលំទូលាយនិងត្រឹមត្រូវ

៥.៤.១. រៀបរៀងវេយ្យាករណ៍ខ្មែរស្តង់ដានិងធ្វើបច្ចុប្បន្នកម្មវចនានុក្រមភាសាខ្មែរនិងសទ្ទានុក្រមបច្ចេកសព្ទ។

៥.៤.២- អភិវឌ្ឍនិងបង្កើតពាក្យថ្មីៗនៅក្នុងជំនាញនិងវិស័យផ្សេងៗ។

៥.៤.៣- ពិនិត្យតាមដាននិងកែតម្រូវការប្រើភាសានិងអក្សរខ្មែរ។

**៥.៥- កំណត់និងត្រួតពិនិត្យឱ្យមានឯកភាពក្នុងការប្រើភាសាខ្មែរ**

៥.៥.១- កំណត់គោលការណ៍នានាឱ្យមានឯកភាពក្នុងការប្រើភាសាខ្មែរ។

៥.៥.២- ត្រួតពិនិត្យនិងកែតម្រូវការប្រើភាសានិងអក្សរខ្មែរ។

**៥.៦- ជំរុញនិងលើកកម្ពស់ការស្រាវជ្រាវ ការប្រមូល ការចងក្រង ការថែរក្សា និងការផ្សព្វផ្សាយឯកសារទាក់ទងនឹងភាសាខ្មែរ**

៥.៦.១- លើកកម្ពស់ការស្រាវជ្រាវ ការប្រមូល ការចងក្រងឯកសារទាក់ទងនឹងភាសាខ្មែរ។

៥.៦.២- អភិរក្សឯកសារទាក់ទងនឹងភាសាខ្មែរ។

៥.៦.៣- ពង្រីកការផ្សព្វផ្សាយឯកសារទាក់ទងនឹងភាសាខ្មែរ។

## ៦- ផែនការសកម្មភាព

ដើម្បីសម្រេចបានយុទ្ធសាស្ត្រខាងលើ ត្រូវមានសកម្មភាពដូចខាងក្រោម៖

### ៦.១- ការបង្កើតយន្តការ

ដើម្បីគាំទ្រដំណើរការអនុវត្តគោលនយោបាយជាតិស្តីពីភាសាខ្មែរ ត្រូវបង្កើតយន្តការដូចខាងក្រោម៖

៦.១.១- ក្រុមប្រឹក្សាជាតិទទួលបន្ទុកភាសាខ្មែរ មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

៦.១.២- គណៈកម្មការបច្ចេកទេសសម្រាប់កិច្ចដំណើរការការងារតាមការចាំបាច់។

៦.១.៣- គណៈកម្មការអន្តរក្រសួងទទួលបន្ទុកត្រួតពិនិត្យការប្រើភាសានិងអក្សរខ្មែរ។

៦.១.៤- ក្រុមការងារចំពោះកិច្ច។

### ៦.២- ការបង្កើតក្របខណ្ឌគតិយុត្ត

ដើម្បីគាំទ្រដំណើរការអនុវត្តគោលនយោបាយជាតិស្តីពីភាសាខ្មែរ ត្រូវបង្កើតក្របខណ្ឌគតិយុត្តដូចខាងក្រោម៖

៦.២.១- លិខិតបទដ្ឋានគតិយុត្តស្តីពីការបង្កើតក្រុមប្រឹក្សាជាតិទទួលបន្ទុកភាសាខ្មែរ។

៦.២.២- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រើភាសានិងអក្សរខ្មែរ។

៦.២.៣- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្កើតគណៈកម្មការឬក្រុមការងារទាក់ទងនឹងភាសានិងអក្សរខ្មែរ។

### ៦.៣- ការគាំទ្រហិរញ្ញវត្ថុ

ដើម្បីគាំទ្រដំណើរការអនុវត្តគោលនយោបាយជាតិស្តីពីភាសាខ្មែរ ត្រូវមានធនធានហិរញ្ញវត្ថុដូចខាងក្រោម៖

៦.៣.១- ថវិកាជាតិដែលជាកញ្ចប់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ឬថវិកាជាតិដែលជាកញ្ចប់ថវិការបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

៦.៣.២- អំណោយនិងវិភាគទានពីដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងសប្បុរសជននានា។

### ៦.៤. ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីគាំទ្រដំណើរការអនុវត្តគោលនយោបាយជាតិស្តីពីភាសាខ្មែរ ត្រូវមានធនធានមនុស្សនិងការបណ្តុះបណ្តាលដូចខាងក្រោម៖

៦.៤.១. ឥស្សរជនដែលមានចំណេះដឹងនិងបទពិសោធផ្នែកភាសាខ្មែរ។

៦.៤.២. អ្នកជំនាញគ្រប់វិស័យទាក់ទងនឹងបច្ចេកសព្ទជាភាសាខ្មែរ។

៦.៤.៣. មន្ត្រីក្របខណ្ឌនិង/ឬមន្ត្រីជាប់កិច្ចសន្យា។

៦.៤.៤. ការបណ្តុះបណ្តាលលើកកម្ពស់ស្មារតីស្រឡាញ់ភាសាជាតិ និងលើកកម្ពស់សមត្ថភាពទាក់ទងនឹងភាសាខ្មែរ។

### ៦.៥. ដំណើរការអនុវត្តគម្រោង

ក្នុងដំណើរការអនុវត្ត**គម្រោងនេះ** ត្រូវរៀបចំជាផែនការសកម្មភាពសម្រាប់ការងារនីមួយៗ ដែលចែកជាផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែង។

## ៧. ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីភាសាខ្មែរ ស្ថាប័នពាក់ព័ន្ធត្រូវ៖

៧.១. បង្កើតយន្តការសម្រាប់ការតាមដានត្រួតពិនិត្យ កែតម្រូវ និងការវាយតម្លៃលើការអនុវត្តគោលនយោបាយនេះ ដើម្បីវិភាគលើលទ្ធផលនៃការងារប្រតិបត្តិ បូកសរុបលទ្ធផលការងារដែលសម្រេចបាន បញ្ហាប្រឈម និងផលប៉ះពាល់នានា ព្រមទាំងលើកទិសដៅអនុវត្តបន្ត។

៧.២. លទ្ធផលនៃការវាយតម្លៃត្រូវយកជាមូលដ្ឋានសម្រាប់កាកែលម្អការងារប្រតិបត្តិដែលនៅខ្វះខាត ការរកដំណោះស្រាយនៃបញ្ហាប្រឈមនានា ដើម្បីរៀបចំផែនការការងារថ្មីឱ្យបានសមស្រប។

៧.៣. ការវាយតម្លៃប្រសិទ្ធភាពការងារត្រូវធ្វើឡើងក្នុងក្របខណ្ឌក្រុមប្រឹក្សាជាតិភាសាខ្មែរ និងអង្គភាពក្រោមឱវាទនីមួយៗនៃរចនាសម្ព័ន្ធគ្រប់គ្រង។

## ៨. សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិស្តីពីភាសាខ្មែរនេះ ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ឧត្តមភាពភាសាជាតិនិងជំរុញឱ្យមានការឯកភាពគ្នាក្នុងការប្រើភាសាជាតិ ដូចជាសំណេរ អំណាន ការបង្កើតពាក្យកម្ចីពាក្យ ជាដើម ដោយធានាបាននូវការអភិរក្សនិងការអភិវឌ្ឍភាសាខ្មែរ។

គោលនយោបាយនេះ គឺជាការឆ្លុះបញ្ចាំងនូវការធ្វើកំណែទម្រង់របស់រាជរដ្ឋាភិបាលនិងជាផែនទីបង្ហាញផ្លូវសម្រាប់ក្រុមប្រឹក្សាជាតិភាសាខ្មែរ និងក្រសួង ស្ថាប័នពាក់ព័ន្ធ បំពេញបេសកកម្មដ៏ពិសិដ្ឋរបស់ខ្លួន ដើម្បីឈានទៅសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅដែលបានកំណត់។

ក្នុងការអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យ រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថានឹងមានការចូលរួមគាំទ្រពីគ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ទាំងធនធានមនុស្ស ទាំងសម្ភារៈ និងហិរញ្ញវត្ថុ។

# សទ្ទានុក្រម

| | |
|---|---|
| ១- បច្ចេកសព្ទ | សំដៅដល់ពាក្យដែលមានន័យជាក់លាក់សម្រាប់ប្រើក្នុងវិស័យ ឬជំនាញណាមួយ។ |
| ២- ភាសាខ្មែរ | សំដៅដល់ភាសានិយាយ ភាសាសរសេរ និងអក្សរខ្មែរ។ |
| ៣- ភាសាជាតិ | សំដៅដល់ភាសាដែលប្រើជាផ្លូវការក្នុងព្រះរាជាណាចក្រកម្ពុជា។ |
| ៤- រូបសញ្ញា | សំដៅដល់ស្លាកឬផ្លាកយីហោ ផ្លាកពាណិជ្ជកម្ម លក្ខណៈសញ្ញា បដា ប៉ង់កាត ប៉ាណូ អាហ្វីស ស្ប៉ុត បណ្ណប្រកាស ខិត្តបណ្ណ អក្សរចាំកែ នៅតាមទីសាធារណៈ ជាដើម។ |
| ៥- ស្តង់ដា | សំដៅដល់ក្បួនខ្នាតគំរូមានលក្ខណៈសមស្របដែលអ្នកប្រើភាសាខ្មែរភាគច្រើនអាចទទួលយកបាន។ |
| ៦- វេយ្យាករណ៍ខ្មែរស្តង់ដា | សំដៅដល់វេយ្យាករណ៍ដែលអ្នកចេះដឹងបានចងក្រងឡើងដោយមានការទទួលស្គាល់ពីសំណាក់អ្នកប្រើភាសាខ្មែរ។ |
| ៧- សុខដុមនីយកម្មភាសាខ្មែរ | សំដៅដល់ការបង្កើតឱ្យមានការស្រុះស្រួលគ្នាលើការប្រើភាសា និងអក្សរខ្មែរ។ |
| ៨- ស្ថាប័ននីយកម្ម | សំដៅដល់ការរៀបចំការងារទាក់ទងនឹងភាសាឱ្យមានរចនាសម្ព័ន្ធនិងការគ្រប់គ្រង ការទទួលខុសត្រូវច្បាស់លាស់ដើម្បីធានានិរន្តរភាព។ |
| ៩- អក្សរឡាតាំងបែបខ្មែរ | សំដៅដល់ការកត់សូរសំឡេងភាសាខ្មែរជាអក្សរឡាតាំងដែលអាចបន្សុីគ្នាបានជាមួយភាសាបរទេស។ |
| ១០- ការអភិរក្សនិងការអភិវឌ្ឍភាសាខ្មែរ | សំដៅដល់ការធ្វើឱ្យភាសាខ្មែរមានការរីកចម្រើនស្របទៅតាមតម្រូវការនៃវឌ្ឍនភាពសង្គម ដោយរក្សាបាននូវអត្តសញ្ញាណភាសាខ្មែរ។/ |